# ការសំភាសន៍របស់អ៊ុំប្រុស ម៉ក់ បាំរាំង

**កៈ អ្នកសំភាសឈ្មោះ សួន សុខលី ខៈ អ្នកត្រូវគេសំភាសឈ្មោះ ម៉ក់ បាំរាំង**

## ការសង្ខេបរបស់អ៊ុំប្រុស ម៉ក់ បាំរាំង

កៈ អ៊ុំប្រុស ម៉ក់ បាំរាំង គាត់មានអាយុ ៦០ ឆ្នាំ។ អ៊ុំប្រុស ម៉ក់ បាំរាំង មានភេទប្រុស។ អ៊ុំប្រុស ម៉ក់ បាំរាំង មានទីលំនៅនាពេលបច្ចុប្បន្ននៅ នៅភូមិ តាកយ ឃុំព្រៃដំបូក ស្រុកសិរីសោធ៌ ខេត្តកំពង់ចាម។ អ៊ុំប្រុស ម៉ក់ បាំរាំង មានកូនទាំងអស់ចំនួន (អត់បានសួរគាត់ទេ)។ អ៊ុំប្រុស ម៉ក់ បាំរាំង បានរៀបអាពាហ៍ពិពាហ៍ នៅឆ្នាំទី៧៩ ខ្វះកន្លះខែទៀតចូលឆ្នាំទី ៨០ គាត់រៀបការនៅជំនាន់ប៉ុលពតទេ ប៉ុលពតគេរៀបអោយគាត់ណា។ អ៊ុំប្រុស ម៉ក់ បាំរាំង មានប្រពន្ធចំនួន ១នាក់ មានឈ្មោះ ជា សុខនី។

កៈ ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំប្រុស ដែលអនុញ្ញាតអោយខ្ញុំធ្វើការសំភាស៍អំពីជីវប្រវិត្តិរបស់អ៊ុំ។ ហើយកាលសំភាស៍នេះគឺធ្វើឡើងដោយសារតែសលកវិទ្យាល័យ BYU ដោយសារតែសកលវិទ្យាល័យនិងចង់ថៃរក្សារជីវប្រវត្តិជីដូនជីតារបស់អ៊ុំ ទុកអោយកូនចៅជំនាន់ក្រោយស្គាប់ ហើយបន្ទាប់ពីការសំភាស៍នេះរួចហើយ តើខ្ញុំអាចសូមដាក់ការសំភាស៍មួយនេះនៅក្នុងប្រព័ន្ធវែបផ្សាយមួយដែលមានឈ្មោះថា www.cambodianoralhistories.byu.edu ហើយខ្ញុំជាអ្នកសំភាស៍អ៊ុំមានឈ្មោះថា សួន សុខលី។ ហើយការសំភាស៍នេះធ្វើឡើងនៅថ្ងៃទី ១៣ ខែ ០៤ ឆ្នាំ២០១៨ ដែលមានទីតាំងនៅ។

កៈ នៅកន្លែងណាដែលអ៊ុំ?

ខៈ ទីតាំងនៅភូមិ តាកយ ឃុំព្រៃដំបូក ស្រុកសិរីសោធ៌ ខេត្តកំពង់ចាម។

កៈ ចារខ្ញុំចង់សួរអ៊ុំប្រុសថា អ៊ុំមាននាមឈ្មោះនិងនាមត្រកូលអ្វីដែលអ៊ុំ?

ខៈ ខ្ញុំបាទឈ្មោះ ម៉ក់ បាំរាំង។

កៈ ហើយឈ្មោះនិងត្រូវជាមួយនិងអតសញ្ញាណប័នអ៊ុំទេ?

ខៈ ត្រូវៗ ត្រូវតាមអតសញ្ញាណប័ន។

កៈ ចារ ហើយអ៊ុំប្រុសមានឈ្មោះហៅក្រៅពីនិងទៀតទេអ៊ុំ?

ខៈ អត់ទេ មានតែមួយនិងគត់។

កៈ ហើយកាលពីក្មេងអីអត់មានដែលអ៊ុំ?

ខៈ បាទ?

កៈ ឈ្មោះតាំងពីក្មេងឪពុកម្ដាយដាក់អោយណា?

ខៈ តាំងពីកំណើត ឈ្មោះពីរដែលប៉ុន្តែ នៅក្នុងឈ្មោះតាមយើងរៀនដាក់ឈ្មោះ ម៉ក់សំឡី ទេណា ប៉ុន្តែធម្មតាគេហៅសាមញ្ញទាំងអស់ហើយ ក្នុងបញ្ជីជាតិគេដាក់ចឹង ក្នុងអតសញ្ញាណប័នក៏ដាក់ចឹងដែល ទូរទៅណា បាទ។

កៈ ហើយឆ្នាំនេះអ៊ុំមានអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំមានអាយុ៦០ អាឡូវនិងអាយុ ៦០ឆ្នាំហើយ។

កៈ ចារចឹងចង់សួរអ៊ុំថា អ៊ុំកើតនៅក្នុង ឆ្នាំអ្វី ខែអ្វីដែលលោកអ៊ុំ?

ខៈ កើតនៅឆ្នាំ១៩៦០ ប៉ុន្មានទេនេះ បើយើងគិតមើល ៦០ឆ្នាំនេះមកដល់សព្វថ្ងៃ ព្រោះខ្ញុំកើតទាន់តាំងពីជំនាន់សីហានុ។

កៈ ចារ ចឹងអ៊ុំទាន់ប៉ុន្មានជំនាន់ដែរអ៊ុំ?

ខៈ ខ្ញុំទាន់ ៤ ជំនាន់។

កៈ ៤ មានជំនាន់អីគេខ្លះដែរទៅអ៊ុំ?

ខៈ មើលនៅជំនាន់ ព្រះសីហានុ ជំនាន់លុននុល ជំនាន់ខ្មែរក្រហម វាឌុបពីរដងមកដល់ជំនាន់សំម្ដេចនេះនិង បាទ។

កៈ ចារហើយចង់សួរអ៊ុំថា ឆ្នាំខ្មែរ អ៊ុំកើតឆ្នាំជូត ឆ្លូវ ឆ្នាំអីដែលអ៊ុំ?

ខៈ ខ្ញុំឆ្នាំចរ។

កៈ ឆ្នាំចរ។ ហើយទីកន្លែងកំណើតអ៊ុំ នៅភូមិណា ឃុំណា ខេត្តណា ស្រុកណាដែរ អ៊ុំ?

ខ៖ នៅភូមិតាកយ ឃុំព្រៃជំបូក ស្រុកសិរីសោធ៏ ខេត្តកំពង់ចាម។

ក៖ ចារហើយ អ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែល?

ខ៖ បងប្អូន ទាំងអស់ ៧ នាក់។

ក៖ អ៊ុំជាកូនទីប៉ុន្មាន?

ខ៖ កូនទី កូនទី៥។

ក៖ កូនទី៥ ហើយអ៊ុំអាចរៀបរាប់ឈ្មោះបងប្អូនអ៊ុំពីកូនទីមួយ រហូតដល់កូនទីប្រាំបានដែរទេអ៊ុំ?

ខ៖ បាទបាន កូនទីមួយឈ្មោះ ជុំ ម៉ក់សារឿន អតីតជាប៉ូលីស នៅសម័យលុននុល។ មកដល់កូនទីពីរឈ្មោះម៉ក់ សារុន ហៅរីន គាត់បានស្លាប់អស់ហើយពីរនាក់និងណា ស្លាប់នៅជំនាន់ប៉ុលពតទាំងអស់នៅឆ្នាំ ៧២ មួយ៧៤ ម៉ក់សារឿននេះងាប់នៅ៧២ ម៉ក់សារុននេះងាប់នៅ៧២ អតីតប្រធានងរ។

ក៖ ចារហើយចឹងខ្ញុំអាច សុំអធ្យាស្រ័យ តើអ៊ុំអាចរៀបរាប់ប្រាប់ខ្ញុំអំពីជំនាន់ដែរអ៊ុំបានឆ្លងកាត់ដូចជាជំនាន់លុននុល ជំនាន់ខ្មែរក្រហមអីតិចបានដែរទេអ៊ុំ?

ខ៖ បាន ខ្ញុំតាំងពីសម័យអើ និយាយតាំងពីសម័យ៧០ មកចុះ យើងមិនបាច់និយាយដល់សម័យខាងនិងទេណា នៅសម័យ៧០ ខ្ញុំនៅរៀនដំបូង ទៅរៀនទៅបានគេបញ្ឈប់រៀនអត់អោយមានសារៀន ក៏ខ្ញុំរត់ចូលកងចល័ត។

ក៖ អ្នកណាគេជាអ្នកបញ្ឈប់អត់អោយមានសាលារៀនអ៊ុំ?

ខ៖ ខ្មែរក្រហម ជំនាន់ខ្មែរក្រហមនិងណា។ ដល់ខ្ញុំរត់ចូលកងចល័តនិងនៅឆ្នាំ៧០ ដល់មក៧១ ៧២ និងក៏ពួកខ្ញុំនិងចាប់ប្រព័ន្ធភ្លឺស្រែ។

ក៖ កាលនិងអ៊ុំមានអាយុប៉ុន្មាន? កាលនិងអ៊ុំចាំទេ?

ខ៖ ខ្ញុំមានអាយុ១៧ឆ្នាំ ដប់១៧ មិនទាន់មួយម្ភៃរទេ ហោចាំខ្ញុំនិយាយសិនចេះជាងគេណា អានិងអាចូលដំបូង ហាហា។ អាយុ១៥ អរអត់ទេ អាយុ១៧ កាលនិង១៧ ដល់កង់ចល័តអើយដូចថាស៊ីបបរមួយពេល ស៊ីបាយមួយពេលអីចឹងទៅ។

ក៖ ចារហើយនៅសម័យនិងគេប្រើអោយអ៊ុំធ្វើអីគេខ្លះទៅអ៊ុំ? អ៊ុំចាំទេ?

ខ៖ ចាំទាំងអស់និង ប្រើតាំងពីយើងកាប់ប្រព័ន្ធភ្លឺស្រែរួច រួចអោយយើងដូចថាលើកដំណាប់ទប់ព្រែកទប់ទន្លេ ហើយគ្រាន់តែទំណាប់វាពីបាតទន្លេរហូតមកដល់លើនិង ៣៧ម៉ែត្រ អានិងនៅខាងក្បាលណា រួចវែកចំងាយដៃរយើងទៅទប់ទំណាប់និង ចំនួនអ្នកដើរទៅនិង ៣០០ ម៉ែត្រទំរាំតែទំណាប់នេះដល់ដី ហាហា មួយត្រលោក។

ក៖ ហើយកាលនៅក្នុងជំនាន់និងអំស្ថិតនៅក្នុងខេត្តណាដែលអុំ?

ខ៖ អើនៅខេត្តព្រៃវែងមួយចំហៀង កំពង់ចាមមួយជំហៀង បាទ។ ព្រោះកាប់ដីពីខាងខេត្តកំពង់ចាមទៅដាក់ខាងព្រៃវែង វាទន្លេ ទន្លេតូចនិងណា កាលនិងវាគួរសមទេ សម័យនិងវាអត់ទាន់មានការលំបាកប៉ុន្មានទេណា ដល់មកលំបាកខ្លាំង អានេះយើងនិយាយកាត់ខ្លះណា និយាយថាយើងចូលព្រៃចុះ ដល់លំបាកខ្លាំងចូលឆ្នាំ៧៧។ ឆ្នាំ៧៧ និងយ៉ាប់ណាស់ព្រោះវាបង្អត់ វាឃ្លាននិង ដូចថាវេទនាមែនទែនណា វាប្រើយើងសព្វគ្រប់សារពើទាំងអស់ មានអាកាច់ពោតលិចទឹក មានអាច្រូតស្រូវនៅក្នុងទឹក ហើយដល់ពេលហូប អោយគ្នាហូបតែបបរ បបរជូនកាលស៊ីជាមួយលង្វរ។

គ៖ ដល់ចឹងទៅយើងទ្រាំវាមិនបាន ចេះតែបេះនេះ បេះនោះស៊ីទៅណាអោយតែមានកម្លាំង។

ខ៖ បាទ ហូបជាមួយលង្វរ រួចដល់ពេលមកទៀត ព្យួជីនិងរួចដល់ម៉ោង (គាត់យំ)។

ក៖ អុំអាចយំអោយអស់ចិត្ត មិនអីទេអុំ។

គ៖ គាត់គិតឃើញនៅកន្លែងកាលវេទនាណា។

ខ៖ លំបាក។

ក៖ ហើយនិយាយចឹងក្រុមគ្រួសារអុំកាលនៅជំនាន់ប៉ុលពត នៅជុំគ្នាឬក៏យ៉ាងមេចដែលអុំ?

ខ៖ បែក បែកគ្នាអស់រលីង នឹកឃើញកាលនិងឪពុកខ្ញុំស្លាប់ វាវេទនាដល់ឪពុកខ្ញុំស្លាប់។

ក៖ ចារអុំអាចនិយាយរៀបរាប់ខ្លះៗបានទេអុំ?

ខ៖ គិតទៅវាប្រើៗយើងទល់តែងាប់ណា ដល់ពេលចឹងខ្ញុំនឹកឃើញចឹងទៅឆ្អែតតែម្តងនិងណា។

ឃ៖ អីគេនិយាយរឿងអី បានយំនិង?

ខ៖ អរនិយាយរំលឹងកាលពីជំនាន់ខ្មែរក្រហម។ រួចដល់ពេលកន្លងមកឪពុកខ្ញុំស្លាប់ចឹងទៅ រោងបាយណាក្មួយ គេបង្កើតរោងបាយ និយាយពីរឿងក្មេងខ្លាំងនិងវេទនាណាស់ តែដល់ហើយអុំនេះចូលតាងធំតិចវិញហើយ ព្រោះគេអោយអុំឡើងធ្វើប្រធានយុវជនណា និងហើយដល់បានធ្វើប្រធានយុវជនយើងប្រើគេវិញម្តង និងហើយយើងនិយាយចេះ ដល់យើងប្រើគេវិញហើយយើងគ្រាន់តែដើរមើលគេ មើលការខុសត្រូវ ដូចថាស្រង់សថិតិចឹងទៅណា និងហើយវាអោយយើងធ្វើចឹង ប៉ុន្តែពួកប្រជាពលរដ្ឋគឺប្រជាពលរដ្ឋវេទនាណាស់ ខុសតែបន្តិចវាអូសក្បាលយកទៅវៃចោល ដល់ប្រជាពលរដ្ឋដេកមួយយប់ៗអោយតែលឺសំលេងរទេះសេស បាទ អោយតែលឺសំលេងរទេះសេសដឹងតែទៀតហើយ ដឹងយកអាណាទៅទៀតហើយ។

គ៖ យកបានដឹកទៅហើយ។

ខ៖ បាទ ទៅទៀតហើយ។

ក៖ កាលនិងគេធ្វើខុសអីបានជាចេះតែយកគេទៅវៃចោលចឹង?

ខ៖ វាៗដូចថានិយាយទៅ ប្រជាជនដូចជាអត់មានខុសអីទេ ប៉ុន្តែដល់ដំណាក់កាលវាត្រូវតែចឹងម៉ងអោយតែយើងដូចថាប្រឆាំងនិងវាតិចនិងក៏មិនបាន ដូចថាតាទាំងពីរនាក់និងណា គ្រាន់តែនាំគ្នានិយាយជុំគ្នាចឹង ដល់យប់តិចវាមកចាប់គាត់យកទៅបាត់។

គ៖ យប់ឡើងនិងដឹងតែបាត់ហើយ។

ខ៖ ដឹងតែបាត់ខ្លួនហើយ។ រួចខ្ញុំនេះ ខ្ញុំធ្វើការដែលប៉ុន្តែខ្ញុំអត់ពីវិធីអីទេ អត់ដឹងថាវាធ្វើអីទេ ដល់តែក្រោយមកទៀត បានខ្ញុំដឹងខ្លួនថា អរអានេះវាសំឡាប់តាមមួយជំនាន់ទៅមួយជំនាន់ណា កាលពេលប្រធានភូមិនៅ វាយកប្រធានភូមិទៅថា ប្រធានភូមិនិងខុសនេះ ខុសនោះ យកប្រធានភូមិមួយសារនិងទៅវៃចោលទៅ។ រួចដល់ពេលខ្ញុំតទៅក្រោយទៀតទៅ អោយខ្ញុំទៅហៅនែកពួកក្រុមយួនណា យួនដែលនៅសេសសល់ពីដើមមកណា សល់តាំងពីសង្គមមកនោះ អោយប្រមូលមកប្រជុំ រួចខ្ញុំ ខ្ញុំដឹងថាបើហៅមកប្រជុំវាដឹងតែសំឡាប់ចោលហើយ ដល់ខ្ញុំមិនទៅវាថា កុំអោយគាត់ទៅខ្លាចទើសទល់ជាមួយកូន ក៏វាអោយអ្នកផ្សេងទៅហៅ និងហើយទៅហៅបីរ បួន ប្រាំនាក់មក ទៅហៅហើយវាថា មកទៅហាត់រៀនក្បួនចិញ្ចឹមទារ ទៅដល់កន្លែង វារឹតនិងខ្សែអង្រឹងណា យកខ្សែអង្រឹងរឹកងាប់តែម្តង។

គ៖ ចុះវាអត់មានសួរនាំអីទេ?

ខ៖ អត់មានសួរនាំអីទៀតទេ យកទៅដល់វាសំឡាប់តែម្តង។

គ៖ អរចឹងនៅក្រុមគ្រួសារយួននុះ?

ខ៖ បាទ អោយតែថាយួនសល់ពីដើមមកណាយកទៅទាំងអស់ ដូចថាវាកាត់ក្លាយប្ដីយកប្រពន្ធខ្មែ យួនយកប្ដីខ្មែរអីចឹងណា វាយកទៅសំឡាប់មួយពូជ យើងនិយាយចេះ វាសំឡាប់មួយពូជ បាទ។

ក៖ ចារហើយដូចជាក្រុមគ្រួសាររបស់លោកអុំមានអ្នកណាខ្លះដែរគាត់ស្លាប់នៅសម័យប៉ុលពតនិងអុំចាំទេ?

ខ៖ ខាងអុំមានស្លាប់បីរនាក់។

ក៖ មានស្លាប់បីរនាក់ មូលហេតុអីបានគាត់ស្លាប់ដែរអុំ?

ខ៖ មូលហេតុដូចថា បងទីមួយ គាត់ធ្វើជាប៉ូលីស កាលនិងយន្ដហោះទំលាក់គ្រាប់បែកមកចំរណ្ដៅតែម្ដង កាលនិងគាត់មកផ្ទះណា គាត់ធ្វើប៉ូលីសសម័យសីហានុណា រួចដល់ឆ្នាំ៧២ និងគាត់ត្រលប់មកស្រុក ដល់គាត់មកស្រុកចឹងទៅ គាត់យកប្រពន្ធថាមកនៅស្រុកនិង គាត់នៅតាំងគោកនេះ (ស្រុកតាំងគោក ខេត្តកំពង់ធំ) មកយកប្រពន្ធនៅតាំងគោកនេះ។ រួចយកប្រពន្ធទៅនៅស្រុកខាងព្រៃដំបូងយើងនោះណា ដល់តែទៅឃើញតាៗអីនិងដើរចូលរណ្ដៅអីជាមួយគ្នា ដល់តែយន្ដហោះវាមកដល់ហើយ ដល់តែយើងចូលទៅអាយន្ដហោះនិងឃើញក៏ទំលាក់គ្រាប់បែកមកចំបណ្ដោយងាប់មួយពូជ អានិងមួយសារទៅ។ រួចដល់តែបងខ្ញុំមួយទៀតនៅឆ្នាំ៧០ដល់តែគាត់ស្លាប់និងមូលហេតុគាត់ធ្វើជាទាហានខ្មែរក្រហមនិងទេណា នៅជំនាន់សម្ដេចគេហៅថា កូនចៅចូលព្រៃម៉ាគីណា បាទ ដល់ចឹងទៅគាត់ក៏ធ្វើជាទាហានខាងនិងគាត់ក៏ទៅផ្ទះប្រធានងរ គាត់កាន់ខាងភូមិភាគណា ជិតបែកហើយនិងស្រាប់តែគ្រាប់ប្លោងមករត់ហ្វែង រួចខ្ញុំនេះក៏ចូលមួយសារទៀត ដល់ចូលទៅមួយសារចឹងទៅគេដកអោយមកវិញ មកផ្ទះវិញ ខ្ញុំធ្លាប់ចូលទាហានមួយសារដែរណាកាលនិង វិលទៅវិលមកវេទនា រួចមកសល់យើងនិយាយពីរឿងមកដល់នេះវិញ កុំអោយនិយាយសារដើមមុខក្រោយ និយាយពីជំនាន់សំឡាប់តែម្ដងទៅ អារឿងសំឡាប់នេះបាន តាទូតខ្ញុំនេះនាំគ្នាបង្កើតឆ្លប់ចូលព្រៃណា ថាតរស៊ូដើម្បីចាប់ខ្មែរក្រហមនិងអាល្អិតល្មោចនិង វានាំគ្នាសំឡាប់ប្រជាពលរដ្ឋទាំងខ្សែៗ មួយខ្សែៗបីរពាន់គ្រួសារ(៣០០០ គ្រួសារ) កាលជំនាន់ខ្ញុំនិងសំឡាប់ខ្លាំងណាស់ ដល់ហើយទៅពួកខ្ញុំនាំគ្នាសារមគ្គីគ្នា នាំគ្នាចូលទៅព្រៃ រួចទៅដល់ចូលព្រៃមានតែកាំភ្លើងអាការបីនតែមួយដើមទៀត មានក្រពះ ក្រពះយើងដេញចាប មានប្រនូង ហើយនិងគល់អាសី រួចក៏ស្រែកទៅ ទៅជំលៀសម្ដងបាន២០០គ្រួសារ ម្ដង២០០គ្រួសារចឹងទៅ ដល់កន្លែងវៃគ្នា យើងដេញវៃវាបណ្ដោយ (វៃជាមួយខ្មែរក្រហម) ដេញវៃវាចឹងទៅ ចឹងក៏រំដោះបានប្រជាជនមកខ្លះ រួចហើយក៏អាក់ខានមួយសារ

ដល់តែអាក់ខានមួយសារក៏វាប្រមូលមករកពួកអាផ្ទៃក្នុងនិងណា អាអ្នកនាំដូចជាពួកខ្ញុំចឹងណា ដល់ហើយពួកខ្ញុំនិងថានៅដេកតែក្នុងផ្ទះទេ រួចហើយនិងប្រមូលទៅទៀតហើយមួយថ្ងៃៗលឺតែសំលេងរទេះគោ រទេះក្របីនិងឌឹតងត់ៗនិងទៅទៀតហើយ យកទៅសំឡាប់នៅនិងវត្ត ទាំងទារហាន និងអតីតទារហានណា ដូចជាខ្ញុំធ្លាប់ធ្វើជាទារហាននិង វាយកទៅសំឡាប់អស់ ៣០០០ នាក់ជាង មានអណ្ដូង មានរណ្ដៅ អាអណ្ដូងយើងដូងទឹកផឹកណា។ រួចហើយនៅវត្តមួយទៀត ទារហានភូមិខ្ញុំវាចាប់បាន ប្រហែលជាមួយពាន់នាក់(១០០០ នាក់) វាដាក់មួយអណ្ដូងទារហានខ្លះ បើប្រជាជនវាសំឡាប់មួយបាំង ពីរកន្លែង បីរកន្លែង នៅនែក ទីមួយនៅវត្តត្បូង ប្រសាទប្ដី ទីពីរនៅវត្តព្រៃជ្រឹង ខាងនិងសំឡាប់ទារហាន ដល់ទីបួននៅអីគេហៅនែក ព្រៃកកំបេះណា អានិងសុទ្ធតែអ្នកធ្វើការ ប្រធានភូមិ មេឃុំ ឆ្លប់ បាទ វាប្រមូលមួយស្រុកនិងទៅសំឡាប់នៅនិង បាទ។ វាដូចថាសំឡាប់តគ្នាណា។

ក៖ ចាសអ៊ុំ។

ខ៖ គ្រូអតីតសល់ពីសម័យលុននុលនិងក៏អត់នៅដែល គឺវាយកទៅសំឡាប់ទាំងអស់ និយាយរួមទៅអោយតែអ្នកចេះដឹង អ្នកណាថាអញចេះ អញដឹង អ្នកនិងគឺងាប់ បើអ្នកណាអួតអាងអ្នកនិងគឺងាប់។

ក៖ ហើយភាគច្រើនយកទៅសំឡាប់ទាំងគ្រួសារក៏យ៉ាងមេចដែរអ៊ុំ?

ខ៖ ជួនកាលវាយកទៅសំឡាប់ទាំងគ្រួសារ ដល់ជួលកាលវាបោកយើងចឹងទៅ យកបានមួយនាក់ពីរនាក់អីនិងទៅ ប៉ុន្តែខាងខ្ញុំ និយាយទៅងាប់ច្រើនបំផុត ពួកខាងធ្វើស្រែ បើខាងទន្លេវិញមិនសូវស្លាប់ទេ បើស្លាប់ ស្លាប់ដោយសារច្រើនតែអ្នកធំ បាទ ដូចថាអតីតធ្លាប់ធ្វើជាទារហានធ្វើប៉ូលីសពីសង្គមអីចឹងណា អានិងងាប់ច្រើន។ រួចមកដល់សម័យខ្ញុំធ្វើជាទារហានទៀត ចុងក្រោយខ្ញុំមកនៅជាមួយតា សំផុន គាត់ខ្សែស្រឡាយពីសម្ដេចសព្វថ្ងៃណា អោយមានលុយចាយ អោយមានបាយហូបចឹងទៅ ដល់ពេលគេដឹងគាត់ចឹងទៅគេតាមកចាប់ គេតាមកហៅយកទៅសំឡាប់នៅកន្លែងគុកទួលស្លែងនេះ ដល់កាលនិងខ្ញុំនៅជាមួយគាត់ គឺថាបានអាចាក់ក្រី អាចាក់ក្រីនិងវាទៅជំនួស ដល់អាចាក់ក្រីទៅលើកទីពីរវាចាប់សំឡាប់តែម្ដងនៅនិងគុកទួលស្លែងនិងណា។

ក៖ ចាសចុះលោកអ៊ុំធ្លាប់បានដឹងខ្លះៗអំពីគុកទួលស្លែងនៅភ្នំពេញនិងមែនអ៊ុំ?

ខ៖ បាទ។

ក៖ ចាសហើយមេចខ្លះដែរអ៊ុំ នៅក្នុងនិង?

ខ៖ កាលនិងអាពួកម៉ាក់ខ្ញុំនិង វាធ្វើខាងដូចថាអង់រក្សរបស់តា សំសុផន និងណា ខ្ញុំនៅជាមួយគាត់នេះទេ ប៉ុន្តែវាចាប់តា សំសុផនទេ តែតា សំសុផននិងគាត់អោយអង់រក្សទៅជំនួសគាត់ដល់ពេលអង់រក្សទៅគេសំឡាប់ចោលមុននិង ដូចថាគេអត់អោយហ្បែងមកទេ គេអោយមេហ្បែងមក ហេតុអីក៏ហ្បែងមក រួចហើយវាសំឡាប់។ ដល់ចឹងធ្វើអីមិនបានក៏យន្តហោះទំលាក់គ្រាប់មក រួចថាតា សំសុផននិងក្បត់ ដល់ពួកខ្ញុំកូនចៅខ្ញុំទារហាននេះមានមួយរយនាក់ណា ដើម្បីការពារទប់ស្កាត់ពួកអាសំឡាប់និងណា តែចាញ់យន្តហោះវានិងតែម្តង រួចហើយ តាសំផុនគាត់សំឡាប់ខ្លួន បាញ់ខ្លួនឯងអោយងាប់ទៅ ខ្ញុំក៏នៅនិងដៃរណា រួចហើយខ្ញុំក៏លើកខ្មោចលើកអីនិងដាក់ឡានទៅតាមឡាននិងបញ្ជូនមក មកដល់កំពង់ចាមយើងនេះ ពួកអាខ្មែរក្រហម វាស្ទាក់ចាប់ វាស្ទាក់ចាប់ខ្មោចនិងណារួចទៅក៏បានវាប្រកាសថា វាចាប់បានហើយ វាចាប់បានវាបាញ់ងាប់ហើយ បាទសម័យនិងហូរហៃលច្រើនណាស់ ក្ជួយអើយ។ រួចហើយបានមកទៀតហើយ ថាខ្មោចប៉ុននេះវាវៃនិងគល់ដូង វាចាប់វៃនិងគល់ដូងរួចវាបោះចូលទៅក្នុងអណ្តូង រួចមក មហាវេទនាហើយ រួចតាំងប៉ុគ្នាទៀតវាប្រើមនុស្សយើងខាងនោះមួយចំហៀងខាងនេះមួយចំហៀង ដូចថាស្រែកតែវានឹកឃើញប្រើអោយយើងធ្វើណា។ និងហើយប៉ុន្តែអាអ្នកធ្វើនិងកន្លងមកក្រោយទៀតមក ក៏ពួកគ្នាវាមួយជាន់ទៀតមក ក៏សំឡាប់អស់ទៅទៀត មិនដឹងជាប៉ុន្មានជាន់ទេ វាសំឡាប់គ្នាបន្តរគ្នានិង ដល់ពេលចុងក្រោយអ្នកដៃរវាសំឡាប់ខ្លាំងជាងគេច្រើនតែពួកមកពីខាងនេះ ខាងតាកែវណា បាទ ខាងតាកែវ។

ក៖ ចារចុះពួកនិងភាគច្រើនប្រើអីគេដែរអុំដើម្បីសំឡាប់?

ខ៖ សំឡាប់ វាប្រើតែពូកថៅ ហើយនិងប្រនូង។

ក៖ ប្រើពូថៅ ហើយនិងប្រនូង។

ខ៖ និងហើយអត់មានថាលីបាញ់ក្នុងក្តាំងអីអត់មានទេ និងហើយពួកនិងវាសំឡាប់នៅមួយកន្លែងៗ វាបញ្ជិះម៉ាស៊ីនភ្លើងនិងភ្លឺព្រាត់ពេញកន្លែងចឹងទៅ វាវៃនិងប្រនូង វៃនិងគល់ដូងទំលាក់ណា មនុស្សចាស់ៗ វាគាប់រណ្តៅហើយស្រេច ដូចថាមួយម្តៃរ សាសិបនាក់និងវាគាប់រណ្តៅហើយស្រេច កាប់រណ្តៅរួចអោយ ឈរនៅនិងមាត់រណ្តៅនិងប្រនូងនិងវាដាក់ផុសៗទៅធ្លាក់ចូលរណ្តៅទៅ អាខ្លះវារឹតនិងខ្សែអគ្រឹងទៅ អាខ្លះវាធ្វើកន្លែងខ្មោះអាករ ថាយ៉ាងមេចក៏ឃើញដែល ឃើញសប់គ្រប់បែបយ៉ាង។ដល់រួចទៅ ចំពោះអ្នកទោសវិញ អ្នកទោសដូចថាមួយនេះខុសលួចស៊ីអីតិចចឹងណា ដូចថាលួចដូង លួចល្មុត លួចផ្លែពោត លួចផ្លែអីចឹងក៏វាយកទៅដាក់គុកដែលអានិង យកទៅវាដាក់អោយស៊ីពោតទុំនិងណា មួយថ្ងៃវាស្ងោរអោយស៊ីមួយចឹងទៅហើយវាធ្វើឬស្សី ដូចជាស្នាច់ចឹងណា និងហើយវាធ្វើរាងដូចស្នាច់ចឹងទៅ វាដាក់មួយសាច់មួយៗអោយមនុស្សម្នាក់ៗរួចដាក់ខ្មោះទាក់ពួកនិង រួចអោយស៊ីទៅ អាខ្លះក៏ឈឺចិត្តងាប់ទៅ អា

ខ្លះក៏ដល់ថ្ងៃវា វាសំឡាប់ចោលទៅ មិនចឹងវាងត់មានវិលមកវិញទេ ដល់វាចាប់ទៅហើយគឺអត់មានវិលមកវិញកើតទេ។

ក៖ ចុះសំរាប់អ្នកនៅក្នុងគុកទួលស្លែងវិញអុំ?

ខ៖ អាគុកទួលស្លែងនិងក៏ដូចគ្នាដែរ បាទដូចជាខ្ញុំនិយាយចឹង។ គុកទួលស្លែងវាយកប្រវិត្តដូចថាខ្ញុំធ្វើជាទារហានចឹងណា ដល់ខ្ញុំធ្វើទារហានចឹង វាចាប់យកទៅនិងវាស្រាវជ្រាវរកតាមគ្រួសារ ហើយវាស្រាវជ្រាវតាមមិត្តភ័ក្តទៀតដូចថា មិត្តភ័ក្តនិងខ្លះគេធ្វើប្រធានករ ខ្លះគេធ្វើប្រធានគរ ខ្លះគេធ្វើប្រធានឯរ ក៏វាចាប់យកមកទាំងអស់ និយាយរួមទៅគុកទួលស្លែងនិងច្រើនតែចាប់អ្នកធំយកទៅដាក់និង បាទសុទ្ធតែប្រធានដំបន់ ប្រធានយោរធា ដូចថាពួកក្រុមសើបការ អោយតែអ្នកខ្សែគេធំៗភាគច្រើនងាប់នៅក្នុងគុកទួលស្លែង បាទ ខ្ញុំមានបងថ្លៃជីដូនមួយម្នាក់ គាត់នៅប្រធានតំបន់មួយជំហៀងខាងនិងឈ្មោះអើ គុយ ធុន និងគេសំឡាប់គាត់នៅគុកទួលស្លែង ដូចថាក្រៅពីនិងវាអត់សំឡាប់នៅគុកទួលស្លែងទេ វាសំឡាប់បំបិទ តែមិនដឹងថាសំឡាប់នៅកន្លែងណាខ្លះទេ អត់តែគុយ ធុន មួយវាសំឡាប់នៅទួលស្លែង ក្រៅពីនិងដឹងសំឡាប់នៅកន្លែងណាខ្លះទេ។ គុយ ធុននិងអតីតខ្មែរក្រហមដែរ អានិងសុទ្ធតេពួកមេពួកអ្នកសំឡាប់ទេ មេពីដំបូងដូចថាតាំងពីជំនាន់សីហនុមកណា តាំងពីជំនាន់សំម្តេចនុះ សម្តេចស្រែកថាកូនចៅចូលព្រៃបាតីនោះ វាធ្វើការតាំងពីនិងមក ដល់យូៗទៅវាចង់បំបាត់ពួកអាមួយក្រុមនិងមួយសារអោយអស់ វាមកចាប់អាថ្មីនិង អាថ្មីនិងវាចាប់សំលាប់តែម្តង វាចាប់ប៉ុលពតឡើងធ្វើនយោករដ្ឋមន្ត្រីនិងណា ប៉ុលពតពួកតាម៉ុកពួកអីនិង ពួកតាស៊ីសុផុន ពួកអីនិង ខ្លះណៃក នួន ជានៅដល់សព្វថ្ងៃនេះ អានិងសរីក្រោយ។

ក៖ ចារ ខ្ញុំឆ្ងល់ថាប៉ុលពតនិងដំបូងអ្នកណាគេជាអ្នកនេះឡើងដើម្បីអោយមានអាពួកនិងឡើងមកណាអុំ ខ្ញុំចង់ដឹង?

ខ៖ ពីដំបូងពាក្យថាប៉ុលពតនោះ មិនដែរលឺឈ្មោះទេ អត់ដែលលឺឈ្មោះសោះ ស្រាប់តែដល់មកពេលអាកាប់សំឡាប់និង ស្រាប់តែលឺចេញឈ្មោះ ប៉ុលពត ហើយនិងតា ម៉ុក។

ក៖ ចារ។

ខ៖ ស្រាប់តែចេញឈ្មោះ ប៉ុលពត ហើយនិងតាម៉ុក។

ក៖ ចារហើយ ប៉ុលពតនិងជាមេគេ?

ខ៖ អើ តាម៉ុក ផ្នែកទាហ៊ាន ប៉ុលពត គាត់ជានយោករដ្ឋមន្ត្រីចឹងណា។ តាម៉ុក សំសេន នួនជា អីនិងណា អានិងវាដូចជាផ្នែកនេះ ខាងនោះទៅណា មកចេញសារក្រោយនេះ អាជិតចប់ងាប់ ហើយនិង ពីដើមមកអត់ទេ ដល់តែផុតពីគេយកពួកខ្ញុំទៅ គេយកសំឡាប់ចោលអស់ទៅអានិង វាខាងបក្សសីហនុណា បក្សខាងសំម្តេចដំបូងមកនោះ ដល់តែពេលនេះទៅ វាសំឡាប់ពួកអស់ និងចោលមួយសារទៅរួចហើយបានកើតមកមួយសារទៀត វាក៏សំឡាប់ចោលមួយសារទៀត ទៅ ដល់ទៅបីរសារបានមកដល់ជំនាន់លុននុលនិង អរអត់ទេជំនាន់ប៉ុលពតនិងតែម្តង បាទ ជំនាន់ប៉ុលពតនិងគឺជំនាន់តាម៉ុកនិងម៉ង ដល់ប៉ុលពតនិង តាម៉ុកចេញមក ក៏ស្លាប់មនុស្សច្រើន តែម្តង គឺស្លាប់ខ្លាំងតែម្តង វាចង់បំបាត់ពូជណា ចង់បំបាត់ពូជខ្មែរណា។

ក៖ ចារ ហើយនិយាយចឹង ដូចជាឪពុកម្តាយរបស់អុំណា ម្តាយអុំមានឈ្មោះអីគេដែរអុំ?

ខ៖ អើ ម្តាយខ្ញុំឈ្មោះ ថង់ នួន។

ក៖ ចារហើយចុះឪពុកអុំមានឈ្មោះអី?

ខ៖ អើឪពុកខ្ញុំមានឈ្មោះ ម៉ក់ ជឿន។

ក៖ ចុះគាត់ទាំងពីរមានអាយុប៉ុន្មានហើយអាឡូវនិងអុំ?

ខ៖ ពួកគាត់ ស្លាប់អស់ហើយ។

ក៖ គាត់ស្លាប់នៅជំនាន់ណាដែល?

ខ៖ គាត់ស្លាប់នៅ អើឪពុកខ្ញុំស្លាប់នៅជំនាន់ប៉ុលពត ឆ្នាំ៧៧ គាត់មានអាយុ៦៧ ឆ្នាំ អអត់ទេ ៦៨ឆ្នាំ។

ក៖ ចារចឹងគាត់ស្លាប់នៅជំនាន់ប៉ុលពតនិងវៃចោលឬក៏?

ខ៖ គាត់គេអត់វៃចោលទេ គាត់ស្លាប់ដោយពិបាកចិត្ត គាត់ដូចថាគេប្រើគាត់ខ្លាំងពេកណា គាត់មានរទេះគោរមួយដឹកលិច កើត ណាមួយគាត់ដូចថាហូបអីទៅខុសចំនី ដែរគេហៅថាដូច ជាអាជំងឺឆ្លតងឺនិងណា តោងរើសមក ក៏គាត់ស្លាប់ទៅ។

ក៖ ហើយចុះម្តាយអុំវិញ?

ខ៖ ម្តាយខ្ញុំនៅ ទើបតែគាត់មកស្លាប់និងប៉ុន្មានឆ្នាំនេះទេ គាត់ទើបតែស្លាប់ ប្រាំរពីរ ប្រាំបីរឆ្នាំ នេះ គាត់ទើបតែស្លាប់ទេព្រោះគាត់នៅតែងង កូនចៅគេបែកអស់ហើយ។

កៈ ចារួចចុះអុំដឹងថាពួកគាត់កើតនៅស្រុកណាខេត្តណាដែរឬទេអុំ?

ខៈ នៅស្រុកជាមួយគ្នានិង គ្រាន់តែនៅឃុំផ្សេងគ្នា មួយនៅឃុំឬស្សីស្រុក មួយទៀតនៅឃុំព្រែកដំបូក បាទ នៅជិតគ្នានិង ឆ្ងាយពីគ្នា ពីបីគីឡូដី។

កៈ រួចចុះឪពុករបស់អុំគាត់គឺជាមនុស្សយ៉ាងម្ដេចដែរ សំរាប់អុំដែរអុំស្រលាញ់?

ខៈ ឪពុកខ្ញុំគាត់ល្អណា បើម្ដាយខ្ញុំគាត់ចិញ្ចឹមកូនប្រាំមួយ ប្រាំពីរនាក់គាត់មិនអោយខ្វះអី កូនគេខ្លះអត់បានរៀនទេណា គាត់វិញអត់ទេ អោយកូនបានរៀនបានសូត្រ សុទ្ធតែអ្នកចេះដឹងទាំងអស់ កូនមួយៗ បងស្រីខ្ញុំនៅដល់សព្វថ្ងៃ ប្អូនប្រុសខ្ញុំងាប់មួយកាលពីឆ្នាំទៅ ងាប់មួយនិងដោយសារឈឺណា មួយនៅសៀបរាម។ ខ្ញុំអតីតខ្ញុំពីដើម ខ្ញុំមិនមែនជាអ្នកខ្សត់ខ្សោយអីដែរ គេហៅថាធន់កណ្ដាល ធន់ល្មមណា ឪពុកម្ដាយខ្ញុំធ្វើចំការទេ ប៉ុន្តែកូនចៅសុទ្ធតែជាអ្នកចេះដឹងតាំងអស់ ខ្ញុំជំនាន់អតីតសម្ដេចសីហនុពីសង្គមនិងខ្ញុំរៀនថ្នាក់ទី១០ ដល់ខ្ញុំចូលថ្នាក់ទី៩ គេបាត់កម្មតែម្ដង បាទ ចូលថ្នាក់ទី៩ បានមួយអាទិត្យនិងគេបាត់តុកម្ម។

កៈ ថ្នាក់ទី៩ នៅឆ្នាំកាលនិង និងនៅជំនាន់នេះស្មើរនិង យើងថា្នក់ទីប៉ុន្មានដែរអុំ? គេរាប់ថយក្រោយឬក៏យ៉ាងមេច?

ខៈ គេរាប់ថយក្រោយ។

កៈ ចារហើយអុំបានចង់ចាំសាច់រឿងអីគេខ្លះអំពីឪពុកម្ដាយអុំ កាលគាត់នៅរស់ថាគាត់បានធ្វើអីគេខ្លះសំរាប់កូនចៅណា?

ខៈ គាត់ដូចខ្ញុំនិយាយចឹង ថាគាត់ធ្វើស្រែ ចំការអីចឹងទៅណា ដើម្បីចិញ្ចឹមកូនអី កូនធំធាត់ឡើងដូចថាកាត់បានផ្ដល់លុយកាក់អោយកូនបានរៀនសូត្រនៅភ្នំពេញ នៅអីចឹងទៅណានិងហើយ អតីតបងប្អូនខ្ញុំនិង និយាយរួមឪពុកម៉ាអីគេសុទ្ធតែនៅភ្នំពេញ គេធ្វើការសម័យសម្ដេចសីហនុណាតែប៉ុននិង ដល់ពេលមកសម័យលុននុលនិងគេប្រមូលមកវៃចោលអស់ហើយដល់តែបែកពីលុននុលមកចូលដល់ស្រុកយើងនិង ក៏បាត់អស់ទៅ និយាយទៅថាងាប់តែម្ដងទៅ ខ្ញុំខ្ជិលនិយាយ បាត់មួយគ្រួសារទៅ ក្រៅពីនិងដឹងតែងាប់អស់ហើយ អ្នកដែរស្លាប់មួយគ្រួសារនិងអតីតពីដើមគាត់នៅសៀមរាមយើងនេះ នៅទួលស្រែង គាត់ធ្វើជាពូលីសនៅទួលស្រែងនិង។ បាទ គាត់បាត់តាំងពីជំនាន់និងមកអត់ឃើញនៅផ្ទះសោះ មិនដឹងទៅណាបាត់ដល់សព្វថ្ងៃនិង។

កៈ ហើយសំរាប់ជីដូនជីតាអុំវិញ ខាងឪពុកមានឈ្មោះអីអុំចាំទេ?

ខ៖ ចាំតែតា។

ក៖ ចាំតែតា ចុះគាត់មានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖ គាត់ឈ្មោះ តាម៉ក់។

ក៖ ខាងឪពុកឬក៏ខាងម្តាយ?

ខ៖ ខាងឪពុក។

ក៖ ចុះខាងម្តាយវិញ?

ខ៖ ខាងម្តាយ តាឈ្មោះ តាថោង។

ក៖ ហើយពួកគាត់ស្លាប់នៅជំនាន់ណាដែរ តើអ៊ុំចាំទេ?

ខ៖ ជំនាន់ ខ្ញុំទាន់ដែរ ប៉ុន្តែខ្ញុំដូចថានៅតូចៗពេក មិនសូវចាំទេ វ៉ៃនៅតូចៗពេក ខ្ញុំដល់សួរចឹងបានចេះតែនឹកឃើញ បើនិយាយទៅរវល់តែស្លាប់ចំហរម៉ាត់ទេ។ តាំងពីខ្ញុំធ្វើទារហានវៃគ្នានៅព្រៃកតាម៉ាក់អីឆ្អែតហើយ។

ក៖ ចារ ចុះអ៊ុំនៅកាលនិងអ៊ុំធ្វើទារហានដែល?

ខ៖ ធ្វើទារហាន កាលនិងខ្ញុំធ្វើបានធ្វើជាទារហាននិងបានសុខសប្បាយនេះ ព្រោះសម័យអោយតែអ្នកស្បែកសរ គឺវាយកទៅវៃចោលហើយ អោយតែអ្នកមានស្បែកសរ។

ក៖ ស្បែកសរនិងមេចបានជាវាយកទៅវៃចោលនិងអ៊ុំ?

ខ៖ ស្បែកសរនិងវាថាចិន វាថាពួកចិន រួចខ្ញុំនៅជំនាន់និងមួយគ្រួសារខ្ញុំ ហាហារ សុទ្ធតែពួកស្បែកសរ សុទ្ធតែចៅចិនណា និងហើយ។

ក៖ ចារហើយអើទាក់ទងអំពីក្រុមគ្រួសារអ៊ុំ បងប្អូនអ៊ុំដែលពួកគាត់នៅរស់ អាឡូវតើពួកគាត់ស្នាក់នៅខេត្តណាខ្លះដែល?

ខ៖ អើមួយនៅកំពង់សោម បង បងស្រីណា អាឡូវកាត់ចោលអ្នកស្លាប់ហើយ និយាយពីអ្នកនៅរស់វិញម្តង បងស្រីមួយត្រូវជាបងខ្ញុំទីពីរនៅកំពង់សោម នៅកំពង់សោមនិងអត់នៅក្រុងទេ នៅចំការដូងនិង ឈ្មោះរិទ្ធធី មួយទៀតនៅភ្នំពេញ បងទីពីរ រួចបានខ្ញុំមកនៅក្នុងភូមិស្រុកខ្ញុំ អតីតខ្ញុំតាំងពីឆ្នាំកៅសិបមក ខ្ញុំធ្វើមេភូមិ មកដល់សព្វថ្ងៃនេះខ្ញុំរត់ចេញរកស៊ីមកដល់កន្លែង

នេះមក ខ្ញុំសុំច្បាប់គេឈប់ទៅណា បាទ ប៉ុនន្តែខ្ញុំធ្វើមេភូមិតាំងពីឆ្នាំ៩៣ ចាប់ពីគេបោះឆ្នោត និងមករហូត បើអតីតពីដើមមកកាល៧២ ៧៣ និងខ្ញុំជាទារហានស្រុក។

ក៖ ចារចឹងទាក់ទងជាមួយសាច់ញ្ញាតិ តើអ៊ុំមានសាច់ញាតិដែលរស់នៅប្រទេសក្រៅដែរទេអ៊ុំ?

ខ៖ បាទអត់ អត់មានទេ។

ក៖ អត់មានទេ។ ហើយទាក់ទងអំពីភរិយាអ៊ុំ តើគាត់មានឈ្មោះអីគេដែលអ៊ុំ?

ខ៖ គាត់មានឈ្មោះ ជា សុខនី។

ក៖ ចារ ហើយអ៊ុំបានរៀបអាពាហ៍ពិពាហ៍នៅពេលណា?

ខ៖ នៅឆ្នាំ ៨៨ ជិតចូល ៨៩ អរមិនមែនទេ ៧៨ ៧៩ ខ្វះកន្លះខែទៀតចូលឆ្នាំទី ៨០ អើខ្ញុំរៀប នៅជំនាន់ប៉ុលពតទេ ប៉ុលពតគេរៀបអោយណា។

ក៖ ចារអរប៉ុលពតជាអ្នករៀបអោយទេ។

ខ៖ បាទប៉ុលពតជាអ្នករៀបអោយ។

ក៖ ចុះមានបង្កាប់ថ្លៃជំនួនដែលទេអ៊ុំកាលនិង?

ខ៖ អត់មានទេ ចាប់គ្នាយកតែម្តង អត់មានសិទ្ធការមានលោកមានអីទេ ចាប់ដៃគ្នាដូចថាយើង ទៅប្រជុំចឹង ចាប់ដៃគ្នាយកទៅមួយគូរៗ ជំនាន់អ៊ុំរៀបការនិងមាន ២២៧ គូរ។

ក៖ ចារតើអ៊ុំប្រុសអ៊ុំស្រីមានធ្លាប់ស្គាល់គ្នាពីមុនមកអត់?

ខ៖ នៅភូមិជាមួយគ្នា។

ក៖ នៅភូមិជាគ្នារ ដល់ហើយក៏ប៉ុលពត ចាប់រៀបការ អោយទៅ?

ខ៖ បាទ នៅភូមិជាមួយគ្នាប៉ុលពតចាប់រៀបការ អ្នកណាតវ៉ាអីងត់បានទេ ហ៊ានតវ៉ា វាយកទៅ សំឡាប់។

ក៖ ចារហើយអ៊ុំចេះអាន និងចេះសរសេរភាសារខ្មែរបានច្បាស់ល្អ ដែរទេអ៊ុំ?

ខ៖ បានម៉ាគួរសម។

កៈ បានគួរសម។

ខៈ បាទ។

កៈ ហើយក្រៅពីភាសារខ្មែរ តើអ៊ុំចេះនិយាយភាសារអីផ្សេងទៀតទេ?

ខៈ អត់ចេះទេ។

កៈ ចុះភាសារថៃនុះអ៊ុំ?

ខៈ ថៃបាននិយាយលេឡារនិង អត់ចេះអីផងនិង ហាហារ។

កៈ ខ្ញុំឃើញអ៊ុំនិយាយថៃបាន?

ខៈ គ្រាន់តែស្តាប់គេបាននិង តែខ្ញុំនិយាយវាអត់កើត ហាហារ និងហើយ។ ខ្ញុំដូចខ្ញុំនិយាចឹងថាស្តាយណាស់ ពេលខ្ញុំរៀនបានចូលថ្នាក់ទី៩ ទៅរៀនបារាំងនិង ទើបតែរៀនបានត្រឹម អា បេ សេ ដេ និងទើបបានមួយចប់និង មិនទាន់រៀនបានច្រើនផង ស្រាប់តែវាបាតុកម្មនិងក៏ចែកផ្លូវគ្នាអស់ទៅ មិនទាន់បានចូលស្រះ ចូលប្រកបអីផងនិង ដល់ចឹងអត់បានរៀនទេ។

កៈ ចារកាលអ៊ុំរៀននិង តើអ៊ុំរៀននៅណា?

ខៈ ខ្ញុំរៀននៅស្រុក បាទនៅសាលាព្រៃដំបូក។

កៈ ចារហើយអ៊ុំចាំឈ្មោះសាលាទេអ៊ុំ?

ខៈ ចាំសាលានិងឈ្មោះសាលាព្រៃដំបូក។

កៈ ចារដល់អ៊ុំកំពង់តែរៀនបានគួរសមចឹងទៅ ក៏មានសង្គ្រាមកើតឡើងចឹងទៅ?

ខៈ បាទ បើកាលនិងខ្ញុំរត់ទៅនៅភ្នំពេញ ដូចកាលពួកម៉ាក់ខ្ញុំវានាំគ្នារត់ទៅនៅភ្នំពេញ គេរៀនបានច្រើនណាស់ រួចហើយគេធ្វើគ្រូបង្រៀន អស់ហើយ អត់តែខ្ញុំអត់ទៅ ព្រោះកាលនិងបងខ្ញុំគាត់រត់ពីភ្នំពេញមកវិញ ដូចថាចូលជំនាន់សំម្តេចចឹងណា ជំនាន់សំម្តេច គេហៅថាកូនចៅចូលព្រៃម៉ាគី។ ប៉ុន្តែអ៊ុំនិយាយចន្លោះច្រើនណាស់ អោយតែនិយាយទៅចេះតែនឹកឃើញបណ្តើរៗ ដល់តែទក់ក្រហាលនិងនិយាយមិនបានច្រើន។

កៈ ចារអ៊ុំអាចនិយាយបន្តរទៀតនូវអ្វីដែលអ៊ុំចង់និយាយ?

ខ៖ ដូចថាកាលនៅជំនាន់៧២ ៧៣ អ៊ុំធ្វើទាហានម៉ារិន បាញ់អាម៉ារីន អ៊ុំនៅខាងជើងទឹក គេអោយនៅតែម៉ាត់ទន្លេ ចាំបាញ់ពួកអាម៉ារីន អាម៉ារីនវាដឹកទាហាន ឡើងខេត្តនិងមកកំពង់ចាមណា ជូនកាលដឹកគ្រាប់ ដឹងប្រេង ដឹកអង្ករឡើងមកចឹងទៅ ពួកខ្ញុំនិងរង់ចាំបាញ់អីចឹងណា បាញ់ទៅវាមានលិចចូលទឹកខ្លះ វាមិនលិចខ្លះ ចាប់បានអាម៉ារីនខ្លះ ដល់ពេលចុងក្រោយចាប់បានដោយសារដាក់ខ្សែកាប់ទេ។

ក៖ ចារអ៊ុំកាលនិងរឹកហាត់ គេចាប់យកទៅធ្វើខ្លួនឯង ឬក៏ស្ម័កចិត្ត?

ខ៖ អ៊ុំស្ម័កចិត្ត នៅសម័យនិងស្ម័កចិត្ត ដូចថាសំម្តេចលោកស្រែកពី ប៉េកាំង មកណាថាកូនចៅចូលព្រៃម៉ាគី ចឹងណារួចក៏បបួលគ្នា ម៉ែឪអីអត់មានអូសទាញទេ គឺដេញកូនទៅតែម្តង កូនមានប៉ុន្មានអោយតែមានកូនធំៗនិងដេញកូនអោយទៅ ទៅៗចូលធ្វើទាហាន ទៅចូលធ្វើជាទាហានក៏ស្រួលម៉្យាងដែលកាលនិង បើសិនជានៅតែផ្ទះក៏វេទនាដែល ដល់ពេលមកដល់ការក្តោបក្តាប់របស់អាអ្នកក្រោយនិងណា គឺប្រើយើងស៊ីបាយរួមណា វាមិនមែនស៊ីបាយតាមផ្ទះទេណា វាអោយស៊ីបាយរួម យុវជនអត់អោយនៅដេកជាមួយម៉ែឪទេ អោយតែឈ្មោះថាយុវជន យុវនារីអីនាំគ្នាដេកផ្ទះ ម្នាក់មួយទៅផ្សេងគ្នា ប្រុសៗដេកផ្ទះមួយចឹងទៅ អោយឆ្ងាយពីរគ្នាចឹងទៅ មួយភូមិ ដល់ពេលធ្វើការមានប្រធានក្រុមគេ ដើរមួយក្រុម គេដាក់ទៅនេះមួយក្រុមគេដាក់ទៅនេះចឹងទៅ ដូចខ្ញុំឈប់ពីទាហានមកខ្ញុំនៅជាយុវជននិង ប៉ុន្តែមកដល់ប៉ះសុទ្ធតែកន្លែងខ្លាញ់ណា កន្លែងសុទ្ធតែកន្លែងសំខាន់ៗម៉ងណា ប្រើ ប្រើអត់អោយបាយស៊ី ជូនការម៉ាពូកពីរបីកំប៉ុង អង្ករតែមួយកំប៉ុង ដូចថាមួយខ្ទះចឹង ខ្ទះត្នោតយើងអាធំនិង វាដាក់អង្ករតែពីរកំប៉ុងទេអង្ករ កាលនិងសុទ្ធតែគ្រាប់ពូជ។

ក៖ គេធ្វើបបរអោយហូបមែនអ៊ុំ?

ខ៖ បបរ បបរពោតនិងណា បបរដូចយើងស៊ីនិងណា រួចព្រឹកបាយ ល្ងាចបបរ (ព្រឹកបាយ ល្ងាចបបរ)។

ក៖ រាល់ថ្ងៃចឹងទៅ?

ខ៖ រាល់ថ្ងៃនិង ជូនអី ជូនកាលថ្ងៃណា ថ្ងៃអាទិត្យចឹងទៅវាធ្វើ បង្អែមអោយស៊ីម្តងដែល ធ្វើបាញ់ជំនឿក់និងគេថាជប់លៀងណា វាធ្វើបាញ់ជំនឿក់អីអោយស៊ីម្តងចឹងទៅ។

ក៖ ចារចុះអ៊ុំខ្ញុំលឺសូ ថាអ្នកខ្លះគាត់ស្លាប់ដោយសារអត់ឃ្លានអីនេះអ៊ុំ? មានទេ?

ខ៖ និងមាន អានិងវាចេះ មាន វាខ្លះហូមអត់កើត ដល់តែហូមអត់កើត វាប្រើខ្លាំង ដល់ចឹងដូច ថាវាស៊ីរបស់និងទៅអត់រួចណា ស្តមទៅ រីងរៃទៅៗក៏ងាប់ទៅ ជួនកាលទៅកន្លែងខ្លះវាប្រើអោយស៊ីម្តងហើយវា វៃដុំច្រំធាក់ទៀត និងហើយដូចថាយើងប្រើសត្វគោរចឹង ថាហ្អែងទៅមុខទៅ ហ្អែងមិនទៅមុខអញវៃ វៃចឹងទៅក៏វាដាច់ខ្យល់ទៅ និងហើយដាច់ខ្យល់ពេលនិងដូចនៅកន្លែង គេថតជាឯកសារសព្វថ្ងៃណា និយាយអោយខ្លីតិច អត់ខុសទេក្មួយ កុំថាមកនិយាយប្រឌិតរឿង រឿងនេះពិត សាច់រឿងដែលគេលេងពីសម័យនិងគឺអត់ខុសទេ គឺសុទ្ធតែចឹងទាំងអស់ ព្រោះខ្ញុំមកទាន់ ខ្ញុំដឹងទាំងអស់ វាអត់មានអត់ខុសពីសម័យសព្វថ្ងៃដែលគេលេង គេសំដែងចឹងណា (សម្តែងរឿងប៉ុលពត) មិនមែនគេកុហកទេ ដូចក្មេងសព្វថ្ងៃអីនិងអ្នកខ្លះសុទ្ធតែថារឿងប្រឌិត មិនមែនប្រឌិតទេ គេលែងរឿងនិងមែនប៉ុនន្តែរឿងនិងវាជាក់ស្តែង រឿងនិងវាជាការពិត អ្នកដែលដើរតួក្នុងសាច់រឿង អ្នកដែលលេងរឿងនិងសិទ្ធតែរឿងពិត បានគេយកមិកនិងវាជារឿងពិត។

ក៖ ចារ ហើយចុះចង់សួរអ៊ុំថា នៅពេលដែលគេជំលះដាច់ ជំនាន់គេវៃប្តាច់ប៉ុលពតនិងណា តើមានហេតុការណ៍កើតឡើងដែលនៅពេលនិងអ៊ុំ?

ខ៖ ពេលហេតុការណ៍ដែលដាច់និង គឺគេប្រែសង្គមថ្មីហើយ ដូចថាសម្តេចហ៊ុនសែន និងណា សំម្តេចហ៊ុនសែនគាត់ចរចារ ដល់តែវៃដាច់និងគេចែកដី ចែកថ្លីអោយទៅប្រជាពលរដ្ឋ ហើយកាលនិងខ្ញុំធ្វើជាប្រធានភូមិហើយ គេចែកដីចែកថ្លីអោយប្រជាពនរដ្ឋនិង គេអោយទៅអ្នកគ្មានដីក៏មានដីដែល រួចអ្នកពីដើមដូចថាមានដីជាកម្មសិទ្ធខ្លួនឯង និងក៏អត់មានខ្វល់ថាយកដីខ្លួនឯង អីវិញអានិងអត់ទេណា គេចែកនៅក្នុងមួយនាក់បានកន្លះម៉ែត្រ បណ្តោយបាន១គីឡូកន្លះអីចឹងទៅណា និយាយរួមបានមួយម៉ែត្រ បណ្តោយបាន១គីឡូកន្លះនិងអីចឹងទៅ រួចក្នុងដប់អ្នកវាបាន៥ម៉ែត្រដែល តែប៉ុននិងអាចចិញ្ចឹមគ្រួសារយើងរស់ហើយ ហើយគេអត់អោយប្រជាពនរដ្ឋដែលបែកដំបូងនិងក៏គាត់មិនខឹងថា ដីអញ អញយកដីអញវិញអីនិងអត់ទេ គាត់ថាសុំតែមួយរស់ ព្រោះបាក់នៅជំនាន់ប៉ុលពតណា គាត់សុំមួយរស់។ អើយអោយតែបានអោយរស់ប៉ុននិងក៏សប្បាយណាស់ហើយ ហើយប្រជាជននិងក៏មានសិទ្ធដើរទៅរកស៊ី ចង់អ្នកណាដើរអី រកស៊ីអីក៏រកទៅព្រោះស្រុកទូរលំទូរលាយហើយ តែភូមិខ្លះវាចាប់សួរនេះសួរនេះទៅ ដល់ហើយក៏ប្តូរថៅវាយស្រុកមួយទៀត ខាងខ្ញុំនិងប្តូរថៅវាយស្រុកមួយទៀត ថៅវាយស្រុកនិងក៏គេមើលទៅអ្នកដែលមិនធ្វើដីណា ដូចថាដីចែកអោយហើយអត់ធ្វើអីទេជួលអោយគេអ្នកធ្វើ ដល់ចឹងគាត់រំសាយចោលតែម្តង គាត់ប្រកាសថា ដូចថាដីពីរបបសង្គមគេនេះមកណា អត់ធ្វើអីទេយកវិញម៉ងទៅ គាត់ប្រកាសចឹងម៉ង គាត់ទុកតែដីអ្នកស្លាប់និងដីអនកអត់មានម្ចាស់នៅ អានិងដកយកទៅជារបស់រដ្ឋចេះវិញ ទុកចែកអោយអ្នកណាធ្វើអោយអ្នកនិងដែលចង់ធ្វើ ឬមួយអោយពួកកូនថៅប៉ូលីសទារហានដែលស្លាប់ទៅ កូនថៅគេធំទាំងអស់គ្នាណាដូចជាដីស្រែចឹងដែល ដូច

អ្នកអតីតធ្លាប់ចូលធ្វើជាទាហានចឹងទៅបាត់បង់ជីវិត ម្ដាយឪពុកនៅ បងប្អូនអីនៅគេចែកមួយកន្លែងមួយហិតាម្នាក់អីចឹងទៅណា អានិងវាចឹង ដីគេចែកគ្នាចឹងក៏អោយតែបានរស់ដូចសព្វថ្ងៃនិងទៅ ម្នាក់ទាំងខ្ញុំទាំងគេណា អោយតែវាព្រមព្រៀងគ្នាអោយបានស្រួលបួលទៅ និងហើយដល់ចឹងទៅសំម្ដេចហ៊ុនសែនគាត់និងដូចថា គាត់ចេះតែអភិវឌ្ឍន៍ប្រទេសជាតិយើងក៏វាចេះតែរុងរឿងទៅណា។បាទ ដល់ចឹងទៅ អ្នកខ្លះក៏ចូលចិត្តគាត់ អ្នកខ្លះក៏មិនចូលចិត្តគាត់ តែអ្នកដែលមិនចូលចិត្តគាត់និងវាមានច្រើននិយាយអោយចំទៅសុទ្ធតែអ្នកអត់ដឹងប្រវិត្ត អ្នកដែលដឹងប្រវិត្តដូចអ៊ុំ អ៊ុំហ៊ានធានាថាមិនបោះបង់គាត់ចោលទេ។

ក៖ ចារហើយខ្ញុំចង់សួរអ៊ុំទៀតថា អ៊ុំមានមិត្តភក្ដិធំឡើងស្និទ្ធស្នាលជាមួយគ្នាដែលឬទេអ៊ុំ?

ខ៖ មាន បាទ។

ក៖ តើពួកគាត់យ៉ាងមេចដែល តើអ៊ុំចង់ចាំអីខ្លះអំពីពួកគាត់?

ខ៖ គាត់បើនិយាយទៅជិវិតនិងប្រវិត្តអីវាដូចតែគ្នានិង។

ក៖ មានជីវិតកំសត់ដូចគ្នា?

ខ៖ ដូចតែគ្នានិងជីវិតកំសត់មិនខុសគ្នាទេ វេទនាណាស់ទំរាំមកដល់សព្វថ្ងៃនិង គេបានធ្វើធំដូច ហៀប ប៊ុនហៀងអីនិងសុទ្ធតែធ្លាប់ធ្វើជាទាហានជាមួយគ្នាពីដើមណាស់ គាត់សុទ្ធតែអូរខ្លាំងជាងខ្ញុំទៀតនុះ ព្រោះអាសម័យក្រោយរដ្ឋកម្ពុជានេះគេតស៊ូមួយច្បាំងទៀតបានគេខ្លាំងនិង ខ្ញុំដល់តែរដ្ឋកម្ពុជាខ្ញុំស្រួល ខ្ញុំស្រួលវិញ ព្រោះតាំងពីបែកមក ពីឆ្នាំ៨០មក គឺខ្ញុំការប្ដីប្រពន្ធខ្ញុំនិង ខ្ញុំគិតរឿងរកស៊ី ខ្ញុំឈប់រឿងការងារ អាឡូវនិងអីខ្ញុំឈប់ហើយរឿងការងារ ទើបតែគេងោយខ្ញុំឡើងធ្វើជាប្រធានភូមិទេ នៅត្រឹមប្រធានភូមិនិង យើងរកស៊ីបានហើយ រួចក្រៅពីនិងដូចថាគេតស៊ូណាស់ និងហើយគេតស៊ូណាស់ ខ្លះក៏ស្លាប់នៅជំនាន់គោប្រាំ ណាគេជំលៀសមកកន្លែងគោប្រាំ ខ្លះវៃខ្មែរក្រហមម្ដងទៀត ទំរាំបានហ៊ុន សែនគាត់ គេហៅថានេះ ចរចារត្រូវនោះ។

ក៖ ហើយចង់សួរអ៊ុំទៀតថា អ៊ុំធ្លាប់ធ្វើការនៅវាលស្រែទេអ៊ុំ?

ខ៖ ធ្លាប់តា។

ក៖ កាលនៅជំនាន់ប៉ុលពតនិងមែន?

ខ៖ នៅជំនាន់ប៉ុលពតនិងវាលស្រែចំតួរហើយ ទៅកាប់លើកភ្លឺ លើកប្រឡាយអីនិង។

កៈ ចារហើយអ៊ុំមានម្ហូបណាដែលអ៊ុំចូលចិត្តជាងគេ?

ខៈ អារឿងនិយាយនិងសម័យនោះអត់មានគិតរឿងចូលចិត្តមិនចូលចិត្តទេ និយាយរួមអោយតែថាមានបាយស៊ីគ្រប់គ្រាន់ ស៊ីបាយជាមួយអំបិលនិងក៏ឆ្ងាញ់ដែល តែវាអត់បានបាយស៊ីគ្រប់គ្រាន់ស៊ីតែបបរ ស៊ីតែបាយពោត។

កៈ ចារចុះអាឡូវនិងអ៊ុំចូលចិត្តម្ហូប អី?

ខៈ អាឡូវនិងចូលចិត្ត ដូចថាស្រេចតែក្បាល់ចិត្ត សម័យសព្វថ្ងៃនេះស្រេចតែក្បាលចិត្តយើងហើយ ចង់ថាមាន់ស្ងោរក៏មាន់ស្ងោរទៅ ចង់ស៊ីសាច់គោរ ក៏សាច់គោរទៅ និងហើយ។

កៈ ចារហើយអ៊ុំមានអើចំរៀងអីដែលអ៊ុំចូលចិត្តស្តាប់ជាងគេងត់?

ខៈ ចំរៀងខ្ញុំចូលចិត្តស្លាប់នែក និយាយរួមទៅស្លាប់តែសម័យ ស៊ុន ស៊ីសាមុត។

កៈ ស៊ុន ស៊ីសាមុត អ៊ុំចូលចិត្តបទគាត់ច្រើនដែលទេ?

ខៈ និងហើយ ចូលចិត្តច្រើនណាស់។

កៈ អ៊ុំចេះច្រៀងទេ?

ខៈ អើរចេះប៉ុនន្តែច្រៀងមិនកើតទេ ហាហារ ពីដើមខ្ញុំចេះលេងស្គរតាស់។

កៈ ចារអ៊ុំធ្លាប់ដែល?

ខៈ អ៊ុំធ្លប់។

កៈ ចារចុះអ៊ុំធ្វើអីកាលនិង?

ខៈ កាលនិងគួរ ល្ខោននិយាយ។

កៈ អរល្ខោននិយាយ គួរល្ខោន។

ខៈ អ៊ុំធ្លាប់លេងរឿងខ្មែរក្រហមដែលនិងណា និយាយពីរឿងអ៊ុំកាលនៅជំនាន់ខ្មែរក្រហមនិងណា ប៉ុន្តែអ៊ុំនិយាយពីរឿងអាកាប់សំឡាប់គ្នាអីដែរនិង ហើយមកដល់អាជំនួយជួញអូរ យើងនេះ បាទ។

កៈ ហើយអ៊ុំចេះលេងឧបករណ៏ភ្លេងខ្មែរ ឬក៏ភ្លេងសម័យអីអត់?

ខ៖ អត់ទេ អុំអត់ចេះទេ ប៉ុន្តែអុំពូកែខាងទិញរបស់អោយគេលែង ខ្ញុំដូចថា បើនិយាយងថា ថៅកែណា។

ក៖ ហើយអុំតាំងពីក្មេងរហូតមកដល់អាឡូវណា តើអុំមានឃើញជីវិតរបស់អុំផ្លាស់ប្តូរអីគេខ្លះ អត់អុំ?

ខ៖ អុំផ្លាស់ប្តូរច្រើនណាស់ ដូចថាយើងចាស់ទៅខ្សោយ ដូចថាកម្លាំងយើងកាន់តែខ្សោយណា បាទ។

ក៖ ហើយអុំធ្លាប់ឆ្លងកាត់ប្រវិត្តជូរចត់ច្រើនណាស់។

ខ៖ បាទឆ្លងកាត់ច្រើន បើនិយាយរួមទៅខ្ញុំ ប្រវិត្តដែលខ្ញុំជូរចត់និងមានតាំងពីឆ្នាំ ៧០ មករហូត តាំងពីឆ្នាំ៧០ ពីនៅអាយុ១៣ ១៤ឆ្នាំអីនុះ។ បាទ តាំងពីនៅជំនាន់១៣ ១៤ឆ្នាំនុះ តាំងពីនិង មករហូតដល់ពេល អើអាយុមួយម្ភៃរប៉ុនន្មានទេ អាយុ២០ បានជ្រះស្រលះខ្លួន។

ក៖ ចារ ហើយចុះអុំចេះជុសជុលនិងចេះសាងសង់ផ្ទះដែលឬទេអុំ?

ខ៖ ចេះ ខ្ញុំចេះដែលតាស ចេះតាំងពីតូច ហាហារ។

ក៖ ចារហើយភាគច្រើនអុំធ្វើជុសជុលផ្ទះខ្លួនឯងអីអុំចេះនុះ?

ខ៖ បាទចេះ។

ក៖ ចេះ ចុះអុំប្រើសំភារះអីគេខ្លះដើម្បីធ្វើអុំ?

ខ៖ មានពូថៅ មានអាញ័រទៅ មានអារណាទៅ មានប៉ូលិចអីចឹងទៅណា សំភារះយើងកំប៉ិច កំប៉ុកនិងទៅ។

ក៖ ចារហើយខ្ញុំចង់សួរអុំមួយទៀត ដូចថាតើមានបន្សស់ទុកជំនាញអីពីមុនមក ដែលក្រុម គ្រួសារគេរឹអាករបន្សស់ទុកអោយអុំ ដូចជាការកូរត្នោត វិញរឹល្ល កូស្កុរអីមានដែលឬទេអុំ?

ខ៖ អត់ទេ អានិងអត់ចេះ។

ក៖ អត់ចេះទេ។

ខ៖ ព្រោះជំនាញខ្ញុំ មានជំនាញធំៗណាស់ ជំនាញទីមួយគឺបច្ចេសទេសខាងរកស៊ីនិងគឺខ្លាំង ខ្ញុំអាជីវកម្មក៏ដាំ ដាំថ្នាំកាតាមនិងណា ធ្វើរហូត ធ្វើជាថ្នាំកាតាម ថ្នាំខ្មែរអីនិង បាទខ្ញុំខាងលក់ចឹងៗ។

ក៖ ចារ ថ្នាំនិងគេយកទៅធ្វើអីគេអ៊ុំ។

ខ៖ ថ្នាំនិងគេលេបនិង គេយកទៅដាក់បារី ធ្វើបារី សព្វថ្ងៃនេះអីនិងគេហៅថា ថ្នាំកាតាម ថ្នាំកាតាមនិងគេយកទៅដុតបញ្ចូលលរ អានិងខ្ញុំចេះធ្វើតាំងពីកូន រហូតដល់យកកូនវាទៅដាំ ដាំរួចហើយទៅកាច់វាយកមកដាក់ចំហ៊ុយទៀត។

ក៖ អ៊ុំចេះធ្វើអានិងតាមអ្នកណាគេ?

ខ៖ ចេះតរគ្នាពីគ្រូ មានគ្រូបារាំងពីដើមនិង កាលនិងឪពុកក្មេកខ្ញុំនិងគាត់នៅស៊ីឈ្នួលបារាំងណាប៉ុន្តែខ្ញុំចេះតាំងពីពេលនិងមកដែល ខ្ញុំទៅលបមើលគេធ្វើណា ដល់ពេលជាក់ស្ដែងមកដល់សម័យយើងបែកនេះ ចាប់ផ្ដើមធ្វើខ្លួនឯងតែម្ដង បាទ ចេះតាំងពីនិងមក។

ក៖ ចារតើអ៊ុំអាចប្រាប់ខ្ញុំបានទេ ថាចាប់តាំងពីពេលដែលអ៊ុំលំបាកបំផុតនៅក្នុងជីវិតរបស់អ៊ុំណា នៅពេលណាដែលអ៊ុំ?

ខ៖ និយាយរួមទៅដូចអ៊ុំថាចឹង ពេលដែលពីបាកបំផុត វេទនាបំផុតពីឆ្នាំមើលនៅ ឆ្នាំ៧៦ បើ ៧៧ ៧៨អីវាគួរសមទេ អានិងដូចថាវាពីបាកដែលមិនអត់ពិបាកទេ បើនិយាយរួមតាំងពីឆ្នាំ៧០ មក ធ្វើទាហានគេប្រមូលរ៉ូងមក ដូចថាស៊ីអត់ស៊ីឃ្លាន ត្រូវគ្រាប់ ទៅរំសេវទៅ អាខ្លះដេកដូចថាខ្ទាំងព័តអីចឹងទៅ នាំគ្នាដេកត្រាំទឹក ត្រាំផុកអីចឹងទៅណា និយាយរួមទៅតាំងពីឆ្នាំ៧០ ពី ៧០និងមករហូតដល់ឆ្នាំទី៨៧ ខ្ញុំនិយាយចេះតែម្ដង។

ក៖ ចារនិងជាពេលដែលអ៊ុំពិបាកបំផុត?

ខ៖ បាទពិបាកបំផុត ទ្រាំលំបាកមក បើពីបាកលេខមួយជាងគេគឺនៅឆ្នាំទី៧៨ ហាហារ។

ក៖ កាលនិងអ៊ុំលំបាកអីគេ?

ខ៖ ឆ្នាំ៧៨ ៧៩និង ហាហារ។

គ៖ មកដល់កាលមីនាង?

ក៖ ចារខ្ញុំមកដល់ម្សិលមិញលោកពូ ហាហារ។

ខ៖ ឆ្នាំ៧៨ ៧៩និងគឺថាពិបាកមហារពិបាកហើយ ពិបាកនិងហូបចុក ពិបាកនិងដូចថាយើងធ្វើអីខុសតែបន្តិចនិងក៏វាយកយើងនិងទៅសំឡាប់ចោលដែលណា អានិងវាពិបកចឹង។ ពិបាកណា រួចដល់ពេលយើងមកបែក ចឹងមក ដូចថាវាគ្មានរឿងអីពិបាកទៀត ដូចថាសិទ្ធសិរីភាពយើងរកស៊ីស្រេចតែនិងក្បាលចិត្តយើងចង់រក បាទ។

ក៖ ចារអាឡូវមកសប្បាយវិញ។ ចឹងខ្ញុំសុំសួរអ៊ុំទៀតថា ពេលដែលអ៊ុំសប្បាយបំផុយនៅក្នុងជីវិតអ៊ុំនិងបទពិសោធន៍ល្អៗដែលអ៊ុំជួបនៅក្នុងជីវិត តើមាននៅពេលណាដែលអ៊ុំ? ពេលអ៊ុំសប្បយម្ដង?

ខ៖ ពេលដែលសប្បយចិត្ត និយាយរួមទៅចាប់តាំងពីឆ្នាំទី៨0 និងមកតែម្ដង។

ក៖ ចារសប្បាយដោយសារអីគេដែរអ៊ុំ?

ខ៖ បាទ សប្បាយដោយសារតែស្រុកទេសយើងវារួចផុតពីអាពួកក្បាត់និងអាពួកខូចណា ដូចថាមកសម័យសម្ដេចយើងសព្វថ្ងៃនិងគឺសប្បាយណាស់។

ក៖ ចារខ្ញុំចង់សួរអ៊ុំទៀតថា តាំងពីក្មេងរហូតដល់អ៊ុំធំតើអ៊ុំធ្លាប់មានសង្ឃឹមចង់បានអី ចង់ធ្វើអីពេលដែលអ៊ុំធំឡើងធ្លាប់មានអត់? ដូចជាក្ដីស្រម៉ៃរបស់អ៊ុំ?

ខ៖ ទេដូចថាអ៊ុំកាលពីជំនាន់និង ពេលអ៊ុំធំមកនិងដូចជាធម្មតាដែល អត់គិតអីទេ ធម្មតា។

ក៖ អ៊ុំអត់មានគិតថាចង់ធ្វើជាគ្រូបង្រៀន ជាគ្រូពេទ្យអីដែលទេអ៊ុំ?

ខ៖ អានិងអត់មានបានគិត ព្រោះកាលសម័យនិងវាគិតអត់កើតត្រង់អាអ្វីដែលយើងត្រូវធ្វើនិងព្រោះសម័យយើងបច្ចុប្បន្នពេលដែលថាយើងធំពេញវ័យនេះ អាវ័យយើងត្រូវសិក្សារ ត្រូវរៀននេះ វាបែជាកើតអាវែគ្នា បាញ់គ្នាចឹង ដល់ពេលចេងយើងវារកនឹកក្ដីស្រម៉ៃអីមិនឃើញទេ ដល់ពេលគេបែកមក យើងមានប្ដីប្រពន្ធ មានបានស្រម៉ៃអី បើខំប្រឹងតែរកស៊ី និយាយចេះម្ដងតែ។ បើចង់ធ្វើការងារ បើសិនជាខ្ញុំចង់ធ្វើការងារវិញអត់ខ្វះទេការងារធ្វើ ប៉ុន្តែគេអោយធ្វើក៏ខ្ញុំមិនទៅដែល អ៊ុំអត់ធ្វើទេ គិតខិតខំតែរកស៊ីតែម្ដង ព្រោះធ្លាប់ធ្វើការឆ្អែតហើយណា ចឹងបានថាខំរកស៊ីទៅ មានមុខរបរហើយចេះតែខំប្រឹងតែម្ដងទៅ។

ក៖ ចារហើយខ្ញុំចង់សួរអ៊ុំទផតថា បើសិនជាអ៊ុំអាចផ្ដាំផ្ញើអ្វីមួយទៅកាន់កូនចៅជំនាន់ក្រោយដែលពួកគេនិងស្ដាប់លឺសំលេងរបស់អ៊ុំ នូវការសំភាស៍មួយនេះ តើអ៊ុំនិងនិយាយអ្វីខ្លះប្រាប់ទៅកាន់ពួកគាត់អ៊ុំ?

ខ៖ អ៊ុំមានតែចេះទេ សូមអោយកូនចៅក្មួយៗ បងប្អូនជំនាន់ក្រោយណា យើងមិនមានអីជូនពរទេ មានតេរឿងថា ក្មួយៗខំប្រឹងរៀនសូត្រ កុំនិយាយអ្វីនិងធ្វើអ្វីមិនល្អទៅកាន់ឪពុកម្តាយ ដូចថាយើងត្រូវចេះគោរពទៅតាមច្បាប់ សំខាន់បំផុត គឺគោរពច្បាប់ បាទ ពិព្រោះកាលនៅសម័យអ៊ុំនិងគឺថាមហារវេទនាហើយ ប៉ុន្តែយើងធ្វើតាមច្បាប់ទៅ ច្បាប់គេធ្វើយ៉ាងមេច យើងគោរពនិងធ្វើទៅតាមច្បាប់ទៅណា ហើយខំតែរៀនទៅមិនចេះខុសទេ។ បាទខំសិក្សារទៅអនាគតទៅការសិក្សារនិងហើយដែលនាំអោយជីវិតយើងបានរុងរឿង ដូចអ៊ុំអីនិងវាខុសហើយអ៊ុំស្តាយណាស់ ស្តាយថាមិនបានសិក្សារខ្ពស់និងគេ បានត្រឹមគេហៅថាមួយភាគណា វាងត់បានដល់ពីរភាគ ហាហារ ស្តាយណាស់ព្រោះសព្វថ្ងៃនេះគេអ្នកចេះដឹង សម័យសម្តេចសព្វថ្ងៃនិងបើអ្នកចេះដឹង អ្នកចេះអីនិងគឺល្អហើយ ចឹងបានថាធ្វើយ៉ាងមេចក៏ដោយគិតខំតែរៀនទៅ រឿនសូត្រអោយបានចេះដឹង ហើយកុំបង្ករបង្កើតឈ្លោះគ្នាវាគ្មានប្រយោជ៍នទេ និងហើយ អាគ្រឿញ្ញានអីនិងក៏មិនកើតដែល កុំអោយក្មួយៗជឹក កុំអោយក្មួយៗញៀននាំតែកើតការទស់ទែងគ្នាណា ខូចខួរក្បាល អត់បានរៀនបានសូត្រ ព្រោះអានិងវាបង្រៀនដល់ម៉ែឪវាទៀតណា បាទហើយមិនបាច់ព្លើតព្លើនទេ បើយើងចង់សប្បាយក៏សប្បាយទៅ សប្បាយធម្មតាទៅ កុំព្លើតព្លើនដូចថាជិះម៉ូតូបង្ហោះអីនិង អានិងសុទ្ធតែនាំអោយកើតគ្រោះថ្នាក់ហើយ និងហើយអត់មានអីទៀតទេ។

ក៖ ចឹងអ៊ុំអស់ហើយ ចារ។ ចឹងខ្ញុំសូមអរគុណអ៊ុំប្រុស ដែលអ៊ុំប្រុសបានអនុញ្ញាតអោយខ្ញុំធ្វើការសំភាស៍អំពីជិវប្រវិត្តរបស់អ៊ុំ៕